ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការស្វែងយល់អំពី

សិទ្ធិខាងរូបភាព

នៃ

បុគ្គល

ប្រភព៖ ផកស្រង់ចេញពីវិទ្យុចាវ៉ាំងអន្តរជាតិ (RFI)

Shared by page: Mr. That Chantha
https:///www.facebook.com/thatchantha

សិទ្ធិខាងរូបភាពនៃបុគ្គល

សិទ្ធិខាងរូបភាព គឺជាផ្នែកមួយនៃសិទ្ធិបុគ្គល ដែលទទួលបានការការពារដោយក្រមរដ្ឋប្បវេណី។ មាត្រា ១០ នៃក្រមរដ្ឋប្បវេណីខ្មែរ ចែងថា៖ **"សិទ្ធិរបស់បុគ្គល សំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងទៀត ដែលជាផលប្រយោជន៍ ទាក់ទងនឹងលក្ខណៈបុគ្គល"**។

១-តើអ្វីទៅជាសិទ្ធិខាងរូបភាពនៃបុគ្គល?

សិទ្ធិខាងរូបភាព គឺជាសិទ្ធិរបស់បុគ្គលក្នុងការហាមឃាត់អ្នកដទៃមិនឲ្យថត ឬផ្សព្វផ្សាយរូបភាពរបស់ខ្លួន។ ដូច្នេះ បើទោះបីត្រឹមតែថតរូប ហើយមិនយករូបថតទៅផ្សព្វផ្សាយក៏ដោយ ក៏ជាការរំលោភលើសិទ្ធិខាងរូបភាពដែរប្រសិនបើគ្មានការព្រមព្រៀងពីម្ចាស់រូប។

២-តើអ្នករំលោភលើសិទ្ធិខាងរូបភាពនេះអាចត្រូវទទួលទោសបែបណា?

អ្នករំលោភលើសិទ្ធិខាងរូបភាពអាចនឹងត្រូវទទួលទោសខាងរដ្ឋប្បវេណីផង និងខាងព្រហ្មទណ្ឌផង។ យោងតាមក្រមរដ្ឋប្បវេណី ក្នុងករណីមានការថត ឬផ្សព្វផ្សាយរូបភាពដោយគ្មានការព្រមព្រៀងពីម្ចាស់រូប ម្ចាស់រូបមានសិទ្ធិ៖

- ទាមទារឲ្យបញ្ឈប់ (មាត្រា ១១)៖ ដូចជា ពេលឃើញគេលើកម៉ាស៊ីនថតចង់ថត សាមីខ្លួនអាចហាមឃាត់មិនឲ្យថត។
- ទាមទារឲ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ (មាត្រា ១២)៖ បើសិនជារូបភាពត្រូវបានថតរួចទៅហើយ សាមីខ្លួនអាចទាមទារឲ្យលុបរូបនេះចេញពីម៉ាស៊ីនថតវិញ។ បើសិនជារូបថតនេះ ត្រូវបានយកទៅចុះផ្សាយរួចហើយ (ដូចជាចុះផ្សាយនៅលើទំព័រវិបសៃត៍ជាដើម) ម្ចាស់រូបអាចទាមទារឲ្យដករូបនេះចេញវិញ។
- ទាមទារសំណងការខូចខាត (មាត្រា ១៣)៖ ប្រសិនបើការថតរូប ឬការផ្សព្វផ្សាយរូបភាពនេះ បានបង្កការខូតខាតណាមួយ ម្ចាស់រូបអាចទាមទារសំណងខូតខាតពីអ្នកប្រព្រឹត្តល្មើសបាន។ សិទ្ធិ

ទាមទារសំណងខូតខាតនេះ អាចអនុវត្តព្រមគ្នាជាមួយសិទ្ធិទីពីរខាងលើ មានន័យថា ម្ចាស់រូបអាចទាមទារឲ្យបញ្ឈប់ការចុះផ្សាយរូបភាពផង ហើយអាចទាមទារឲ្យសងការខូតខាតផង។

ក្នុងពេលជាមួយគ្នា អ្នកដែលប្រព្រឹត្តអំពើ ដែលប៉ះពាល់ដល់សិទ្ធិខាងរូបភាពបុគ្គល ក៏អាចត្រូវទទួលទោសព្រហ្មទណ្ឌដែរ។នៅក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា៣០២មានចែងថា**"អំពើថតរូបភាពនៃបុគ្គលនៅក្នុងទីកន្លែងឯកជន ដោយគ្មានការព្រមព្រៀងពីបុគ្គលនេះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែន ទៅ ២លានរៀល លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត"**។

៣-ដូច្នេះមានន័យថា រាល់ពេលដែលចង់ថតរូបអ្នកណាម្នាក់ គឺជាចំណាត់ត្រូវតែមានការព្រមព្រៀងពីសាមីខ្លួនជាមុនជានិច្ចឬយ៉ាងណា?

ជាគោលការណ៍ គឺត្រូវតែមានការព្រមព្រៀងពីម្ចាស់រូបជាមុនសិន ទាំងការថតរូប និងការយករូបថតទៅផ្សព្វផ្សាយ ព្រោះថាការព្រមព្រៀងឲ្យថត មិនមែនមានន័យថា ឲ្យយករូបថតនេះទៅផ្សព្វផ្សាយទេ។ ការព្រមព្រៀងឲ្យថត ឬឲ្យចុះផ្សាយរូបថត អាចជាការព្រមព្រៀងដោយជាក់ច្បាស់ (ម្ចាស់រូបប្រាប់អ្នកថតថា ខ្លួនអនុញ្ញាតឲ្យថតរូប ឬយករូបថតទៅផ្សព្វផ្សាយ) ឬដោយតុណ្ហី (ម្ចាស់រូបដឹងដែរថា គេថត តែមិនជំទាស់ ឬដឹងដែរថា គេយករូបទៅចុះផ្សាយតែមិនជំទាស់ គឺមានន័យស្មើនឹងយល់ព្រមឲ្យគេថតរូប ឬឲ្យគេយករូបថតទៅចុះផ្សាយ)។ ក៏ប៉ុន្តែ អ្នកថតគួរតែស្វែងរកការព្រមព្រៀងឲ្យបានជាក់ច្បាស់ពីម្ចាស់រូប ប្រសើរជាងការព្រមព្រៀងដោយតុណ្ហី ជាពិសេស បើចង់យករូបថតគេទៅផ្សព្វផ្សាយ ពីព្រោះថា បើ គ្មានការព្រមព្រៀងដោយជាក់ច្បាស់ជាមុនទេ ម្ចាស់រូបមិនត្រឹមតែអាចទាមទារឲ្យដករូបនេះចេញវិញទេ ប៉ុន្តែថែមទាំងអាចទាមទារសំណងជំងឺចិត្តទៀតផង។

៤-តើការថតរូបតាពក្រុមមនុស្សរកកុញ ត្រូវតែសុំការអនុញ្ញាតពីម្ចាស់រូបគ្រប់ៗគ្នាឬយ៉ាងណា?

ការថតរូប ឬចុះផ្សាយរូបថតក្រុមមនុស្ស មិនចាំបាច់មានការព្រមព្រៀងពីម្ចាស់រូបនោះទេ ប្រសិនបើក្នុងរូបថតនេះគេមិនអាចមើលដឹងថាជារូបរបស់អ្នកណាច្បាស់លាស់ទេ។ តាមការពិត ទោះបីថតរូបមនុស្សច្រើនគ្នាជាក្រុមក៏ដោយ ឬថតមនុស្សម្នាក់ឯងក៏ដោយ ឲ្យតែមនុស្សក្នុងរូបថត គេមិនអាចមើលស្គាល់ទេ គឺមិនមានការប៉ះពាល់ដល់សិទ្ធិខាងរូបភាពទេ។ដូច្នេះគេមិនចាំបាច់សុំការព្រមព្រៀងពីម្ចាស់រូបទេ។

៥-ការថតឬចុះផ្សាយរូបថតរបស់ មន្ត្រីរដ្ឋាភិបាលក្នុង ទំព័រសារព័ត៌មាន ដោយគ្មានការអនុញ្ញាតគឺជាការប៉ះពាល់ដល់សិទ្ធិខាងរូបភាពដែរឬទេ?

ការថតរូប ឬចុះផ្សាយរូបថត របស់មន្ត្រីដែលកាន់មុខងារសាធារណៈ មិនមែនជាការប៉ះពាល់ដល់សិទ្ធិខាងរូបភាពនោះទេ ប្រសិនបើរូបថតនោះ ត្រូវយកទៅប្រើប្រាស់ក្នុងផលប្រយោជន៍សាធារណៈ។ បុគ្គលដែលកាន់មុខងារសាធារណៈ (ដូចជា រដ្ឋមន្ត្រី ប្រធានស្ថាប័នសាធារណៈ ឬមន្ត្រីនាំពាក្យស្ថាប័នសាធារណៈ ជាដើម) សុទ្ធតែបានដឹងខ្លួនជាមុនថា ខ្លួនអាចត្រូវគេថតរូប និងចុះផ្សាយរូបថត ដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ ដូច្នេះ គេសន្មត់ជាទូទៅថា បុគ្គលសាធារណៈទាំងនោះ បានព្រមព្រៀងជាមុន ឲ្យគេថតរូប និងចុះផ្សាយរូបថតរបស់ខ្លួន។ ប៉ុន្តែ រូបថតនោះអាចប្រើបាន តែក្នុងគោលដៅផលប្រយោជន៍សាធារៈប៉ុណ្ណោះ មិនអាចប្រើក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជន ឬគោលដៅពាណិជ្ជកម្មបានទេ៕

ចប់